## តើខ្ញុំអាចជ្រើសរើស AFH យ៉ាងដូចម្តេច?

បុគ្គល និងគ្រួសាររបស់គេ ឬអ្នកតំណាងស្របច្បាប់ជ្រើសយកអ្នកផ្តល់សេវា។ អ្នកផ្តល់សេវាត្រូវតែបានជ្រើសតាំងជាលំនៅដ្ឋានឯកទេស DD និងចេញអាជ្ញាប័ណ្ណឱ្យដោយ DSHS។

## តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមអំពី AFHs នៅកន្លែងណា?

- អ្នកអាចទូរស័ព្ទទៅការិយាល័យ DDA ប្រចាំតំបន់របស់អ្នក ហើយស្នើសុំនិយាយជាមួយអ្នកគ្រប់គ្រងធនធានករណីរបស់អ្នកបាន។
- អ្នកអាចប្រឹក្សាយោបល់កម្មវិធី Ombudsman ថែទាំរយៈពេលវែង តាមលេខ 1-800-562-6028 ឬចូលមើលគេហទំព័ររបស់ពួកគេ៖ www.ltcop.org
- អ្នកអាចចូលមើលគេហទំព័រ ALTSA នៅ www.altsa.dshs.wa.gov/pubinfo/housing/other/#AFH



**សម្រាប់ព័ត៌មានបន្ថែម ចូលមើលគេហទំព័រ DDA នៅ៖**

**www.dshs.wa.gov/dda**

## តើ DDA មានទីតាំងនៅឯណា?




**តំបន់ 1**
**1-800-462-0624**
TTY (509) 568-3038
1611 W. Indiana Ave.
Spokane, WA 99205-4221
ទូរស័ព្ទ (509) 329-2900

**តំបន់ 2**
**1-800-788-2053**
TTY (360) 714-5002
840 N. Broadway
Bldg. A., Suite 100
Everett, WA 98201-1288
ទូរស័ព្ទ (425) 339-4833

**តំបន់ 3**
**1-800-248-0949**
TTY (253) 572-7381
1305 Tacoma Ave. S.
Suite 300
Tacoma, WA 98402
ទូរស័ព្ទ (253) 404-5500

**តំបន់ 1**
**1-800-822-7840**
TTY (509) 454-4321
3700 Fruitvale Blvd.
Suite 200
Yakima, WA 98909-2500
ទូរស័ព្ទ (509) 225-4620

**តំបន់ 2**
**1-800-314-3296**
TTY (206) 720-3325
1700 E. Cherry St. #200
Seattle, WA 98122
ទូរស័ព្ទ (206) 568- 5700

**តំបន់ 3**
**1-800-339-8227**
TTY (360) 586-4719
Point Plaza East
Bldg. 2, 3rd Floor
6860 Capitol Blvd. SE
Olympia, WA 98504-5315
ទូរស័ព្ទ (360) 725-4250


Washington State
Department of Social
& Health Services
*Transforming lives*

DSHS 22-442 CA (Rev. 8/17) Cambodian


# លំនៅដ្ឋានគ្រួសារ មនុស្សពេញវ័យ (AFH)

## ជំនួយ និងសេវារដ្ឋបាល ពិការភាពខាងការអភិវឌ្ឍ




Washington State
Department of Social
& Health Services
*Transforming lives*

## តើលំនៅដ្ឋានគ្រួសារមនុស្សពេញវ័យជាអ្វី (AFH)?

លំនៅដ្ឋានគ្រួសារមនុស្សពេញវ័យ (AFH) ជាកន្លែងរស់នៅដែលជាកម្មសិទ្ធិ ឬដួលដោយអ្នកផ្តល់សេវាដែលមានអាជ្ញាប័ណ្ណ។ វាផ្តល់នូវបន្ទប់ និងម្ហូបអាហារ ការមើលការខុសត្រូវ 24 ម៉ោង និងការថែទាំផ្ទាល់ខ្លួនសម្រាប់មនុស្សពេញវ័យអាយុពី 2 ដល់ 6 ឆ្នាំ អាយុ 18 ឆ្នាំ ឬចាស់ជាងនេះ។ លំនៅដ្ឋានគឺមានអាជ្ញាប័ណ្ណ និងគ្រប់គ្រងដោយនាយកដ្ឋានសេវាថែទាំការរស់នៅ (RCS) នៃរដ្ឋបាលជំនួយរយៈពេលយូរ និងចាស់ជរា DSHS (ALTSA)។

## តើនរណារស់នៅក្នុងលំនៅដ្ឋានមនុស្សពេញវ័យ?

AFHs គឺអាចរកបានសម្រាប់បុគ្គលអាយុ 18 ឆ្នាំឡើងទៅ ដែលមានសិទ្ធិទទួលបានរដ្ឋបាលពិការភាពខាងការអភិវឌ្ឍ (DDA) ដែលត្រូវការការថែទាំ ការគាំទ្រ និងការត្រួតត្រា។ អ្នករស់នៅអាចទទួលបានមូលនិធិតាមរយៈ DSHS (Medicaid) ឬការទូទាត់ជាឯកជន។ ជាង 1.600 នាក់ដែលមានពិការភាពខាងការអភិវឌ្ឍរស់នៅក្នុង AFHs ក្នុងរដ្ឋវ៉ាស៊ីនតោន។

## តើការបណ្តុះបណ្តាលអ្វីខ្លះតម្រូវឱ្យមានសម្រាប់អ្នកផ្តល់សេវា និងអ្នកថែទាំ AFH?

អ្នកផ្តល់សេវា AFH ទាំងអស់ត្រូវតែបំពេញបាននូវតម្រូវការអាជ្ញាប័ណ្ណ និងការបណ្តុះបណ្តាល (ជំពូក 388-76 WAC)។ អ្នកផ្តល់សេវាដែលមានអាជ្ញាប័ណ្ណ និងអ្នកគ្រប់គ្រងអ្នករស់នៅត្រូវតែបំពេញវគ្គ បណ្តុះបណ្តាលពិសេសផ្នែកពិការភាពខាងការអភិវឌ្ឍ មុនពេលធ្វើការជាមួយអ្នករស់នៅដែលមានពិការភាពខាងការអភិវឌ្ឍ (https://www.dshs.wa.gov/dda/events-and-training/events-and-training)។

- DDA ផ្តល់ជូនការណ្តុះបណ្តាលពិសេស និងជំនួយបច្ចេកទេសនៅក្នុងផ្ទះ។
- បុគ្គលិកប្រចាំតំបន់របស់ DDA ផ្តល់ជូនការត្រួតពិនិត្យការធានាគុណភាពសម្រាប់លំនៅដ្ឋាននានា។

អ្នកផ្តល់សេវា និងអ្នកថែទាំ AFH ទាំងអស់តម្រូវឱ្យបំពេញ

- តម្រូវការបណ្តុះបណ្តាលក្រោម ជំពូក 388-112 WAC។
- ការអប់រំជាបន្តបន្ទាប់ចំនួន 12 ម៉ោងរាល់ឆ្នាំ

## តើអ្វីជាការបណ្តុះបណ្តាលបន្ថែមដែលត្រូវបានផ្តល់ជូនទៅអ្នកផ្តល់សេវា និងអ្នកថែទាំ AFH?

ការអប់រំជាបន្តបន្ទាប់គឺតម្រូវឱ្យមានសម្រាប់អ្នកផ្តល់សេវា និងអ្នកថែទាំ AFH ទាំងអស់។ DDA ផ្តល់ជូនការបណ្តុះបណ្តាលជាក់លាក់មួយចំនួនលើបញ្ហាពិការភាព ជំនួយឥរិយាបថវិជ្ជមាន និងប្រធានបទដទៃទៀត។ ការបណ្តុះបណ្តាលទាំងនេះគឺឥតគិតថ្លៃចំពោះ AFH ហើយអាចរកបាននៅទំព័រវិបឌិកាសការបណ្តុះបណ្តាលអ្នកផ្តល់សេវា DDA ៖

https://www.dshs.wa.gov/dda/events-and-training/events-and-training

## តើ DDA រំពឹងអ្វីខ្លះពីអ្នកផ្តល់សេវា និងអ្នកថែទាំ AFH?

DDA រំពឹងឱ្យអ្នកផ្តល់សេវា និងអ្នកថែទាំ AFH ទាំងអស់ធានាថា អ្នករស់នៅម្នាក់ៗជួបប្រទះនូវ៖

- សុខុមាលភាព និងសុវត្ថិភាព
- សមត្ថភាពក្នុងការគ្រប់គ្រងសកម្មភាពជាប្រចាំថ្ងៃ និងបន្តគោលដៅផ្ទាល់ខ្លួន
- ថាមពល និងជម្រើស
- ឋានៈ និងការរួមចំណែកដោយខ្លួនឯង និងអ្នកដទៃ
- ការរួមបញ្ចូលក្នុងជីវិតផ្លូវកាយ និងសង្គមនៃសហគមន៍របស់ពួកគេ និង
- ទំនាក់ទំនងជាមួយមិត្តភក្តិ និងសាច់ញាតិ។

## តើសេវាអ្វីខ្លះត្រូវបានផ្តល់ក្នុង AFH?

អ្នកផ្តល់សេវា និងអ្នកថែទាំ AFH តម្រូវឱ្យផ្តល់៖

- បន្ទប់ និងម្ហូបអាហារ
- ការមើលការខុសត្រូវ 24 ម៉ោង និង
- ជំនួយជាមួយការថែទាំផ្ទាល់ខ្លួនដូវបានកំណត់ក្នុងការវាយតម្លៃ CARE របស់អ្នករស់នៅ។

អ្នករស់នៅម្នាក់ៗត្រូវតែមានការវាយតម្លៃគ្រប់ជ្រុងជ្រោយ និងរង្វាយតម្លៃរបាយការណ៍ (CARE) ដែលបានបំពេញដោយអ្នកគ្រប់គ្រងធនធានករណី DDA មុនពេលចូល។ ការវាយតម្លៃនេះគឺត្រូវបានធ្វើឡើងជាមួយបុគ្គល និងគ្រួសាររបស់គាត់ ឬនាង ឬតំណាងស្របច្បាប់។ ការវាយតម្លៃរៀបរាប់លម្អិតអំពីសេចក្តីត្រូវការ និងចំណូលចិត្តជំនួយរបស់បុគ្គលសម្រាប់សេវាកម្មនានា ហើយក៏កំណត់នូវកម្រិតថែទាំ និងអត្រាសម្រាប់សេវាកម្មនានាផងដែរ។ ការវាយតម្លៃ និងផែនការសេវាកម្មនេះត្រូវតែបានពិនិត្យឡើងវិញជារៀងរាល់ឆ្នាំជាមួយការសំភាសន៍ផ្ទាល់ដោយអ្នកគ្រប់គ្រងធនធានករណី DDA។ អ្នកគ្រប់គ្រងធនធានករណី DDA ត្រូវតែមកមើលលំនៅដ្ឋានក្នុងពេលផ្សេង បើការវាយតម្លៃនេះមិនបានបំពេញនៅក្នុងលំនៅដ្ឋាន។

លើសពីនេះ អ្នកផ្តល់សេវា AFH តម្រូវឱ្យបំពេញផែនការថែទាំដែលបានចរចា។ នេះគឺជាផែនការថែទាំតម្រូវតាមបុគ្គលដែលបានអភិវឌ្ឍជាមួយបុគ្គល និងគ្រួសាររបស់គេ ឬតំណាងស្របច្បាប់។ ផែនការថែទាំដលែបានចរចារួមមានសេវាកម្ម និងសកម្មភាពនានាដែលបានចរចាររវាងបុគ្គល និងអ្នកផ្តល់សេវា ដូចជា៖

- ជំនួយជាមួយការបញ្ជូនកិច្ចការថែទាំផ្ទាល់ខ្លួន និង
- ការចូលទៅកាន់សកម្មភាពសហគមន៍ ការណាត់ជួបវេជ្ជសាស្ត្រ និងមធ្យោបាយដឹកជញ្ជូន។

## តើនរណាទូទាត់ថ្លៃសេវា AFH?

អ្នករស់នៅត្រូវតែចូលរួមចំពោះថ្លៃចំណាយនៃបន្ទប់ និងម្ហូបអាហាររបស់ពួកគេពីចំណូលផ្ទាល់ខ្លួនរបស់ពួកគេ។ DSHS ទូទាត់ប្រាក់នៅសល់ផ្អែកលើកម្រិតនៃសេចក្តីត្រូវការដែលបានវាយតម្លៃរបស់បុគ្គលម្នាក់ៗ។

## តើនរណាត្រួតត្រាសេវា AFH?

### DDA ផ្តល់៖

- ការគ្រប់គ្រងករណី រួមទាំងការវាយតម្លៃ CARE ដោយផ្ទាល់ប្រចាំឆ្នាំ។
- អ្នកឯកទេសផ្នែកការធ្វើឱ្យប្រសើរដល់ការអនុវត្ត និងគុណភាពប្រចាំតំបន់ជួប AFHs ដើម្បីវាយតម្លៃគុណភាពនៃសេវាកម្មនានា និងដើម្បីផ្តល់ការពិគ្រោះយោបល់ និងការបណ្តុះបណ្តាល។
- គិលានុបដ្ឋាយិកាដែលបានចុះឈ្មោះអាចជួប AFHs ដើម្បីវាយតម្លៃផែនការសេវាកម្ម និងផ្តល់ការពិគ្រោះយោបល់ និងការបណ្តុះបណ្តាលដល់អ្នកផ្តល់សេវា និងអ្នកថែទាំបាន។

### RCS ផ្តល់៖

- អាជ្ញាប័ណ្ណ និងការត្រួតពិនិត្យសម្រាប់ AFHs ទាំងអស់។
- អ្នកផ្តល់អាជ្ញាប័ណ្ណធ្វើការជួបដែលមិនបានប្រកាសមួយដល់រាល់ AFH ដែលមានអាជ្ញាប័ណ្ណម្នាក់ៗយ៉ាងតិចរៀងរាល់ 18 ខែម្តង។
- ការតាមដានលើការរំលោភបំពាននូវបទបញ្ញត្តិចេញអាជ្ញាប័ណ្ណ ដែលអាចជាលទ្ធផលក្នុងការបណ្តុះបណ្តាលបន្ថែម ការពិគ្រោះយោបល់ ការផាកពិន័យ ឈប់ការដាក់ ឬការលុបចោលអាជ្ញាប័ណ្ណ ការដកហូត ឬការផ្អាក។
- ការពោលអះអាងនៃការប្រើរំលោភគឺត្រូវបានយោងទៅកាន់អង្គភាពដោះស្រាយបណ្តឹង (CRU) ហើយបុគ្គលិក RCS ត្រូវបានចាត់តាំងឱ្យធ្វើការស៊ើបអង្កេតបើចាំបាច់។ RCS ក៏ស៊ើបអង្កេតបណ្តឹងទាំងអស់នៃការប្រើរំលោភរបស់អ្នករស់នៅដែលបានហៅទូរស័ព្ទទៅកាន់បណ្តាញទាន់ហេតុការណ៍ CRU តាមលេខ 1-800-562-6078 ផងដែរ។

